**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៨២/០០៥ /២០០៤

ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤

**សេចក្តីសម្រេច**

លេខ : ០៦០/០០២/២០០៤ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតរបស់តំណាងរាស្ត្រ ចំនួន២១រូប ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤" ស្នើសុំពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវ ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទទួលបាននៅ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៤ វេលាម៉ោង ១៥ និង ៤០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា កថាខណ្ឌទី១នៃមាត្រា ១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា " ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ" ។ កថាខណ្ឌនេះពុំមានចែងអ្វីទាក់ទងដល់សមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមទេ ។

-យល់ឃើញថា ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងផ្នែកទី២ ស្តីពីសមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញចំពោះធម្មនុភាពនៃច្បាប់ជាព្រះរាជក្រមដែលចែងលំអិតសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញពិសេសនៅត្រង់ មាត្រា ១៥ បានចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្នុងក្របខ័ណ្ឌ នៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់" ។ មាត្រ១៥ នេះ ពុំមានចែងថាក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចពិនិត្យធម្មនុញ្ញភាពនៃ ច្បាប់ធម្មនុញ្ញបន្ថែមទេ ។

-យល់ឃើញថា សំណើរបស់ ឯកឧត្តម លោកជំទាវតំណាងរាស្ត្រ ចំនួន ២១រូប ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤"ស្នើសុំពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" មិនស្ថិតនៅក្នុង

ក្របខ័ណ្ឌមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុង មាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

- យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញ ធ្លាប់បានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាច្រើន ប៉ុន្តែពុំដែលបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលមានលក្ខណៈជារដ្ឋធម្មនុញ្ញ ដូចជាច្បាប់ធម្មនុញ្ញបន្ថែមនេះទេ ។ ម្យ៉ាងទៀតច្បាប់ធម្មនុញ្ញបន្ថែមនេះជាច្បាប់កំពូលមួយ មានចែងពីគោលដៅរបស់ច្បាប់មានមាត្រានៃច្បាប់ដោយឡែក និង ឋានានុក្រមស្មើនឹងច្បាប់រដ្ឋ-ធម្មនុញ្ញ ឆ្នាំ ១៩៩៣ ទៅហើយ ។ ដូច្នេះច្បាប់ធម្មនុញ្ញនេះ គឺជារដ្ឋធម្មនុញ្ញ ដែលពុំអាចពិនិត្យធម្មនុញ្ញភាពបានឡើយ ។

**សម្រេច**

**មាត្រា ១** ៖ យោងតាមមូលបទខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ការពិនិត្យធម្មនុញ្ញភាពនៃ " ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ " ពុំមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

**មាត្រា២** ៖ សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាច ទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**